**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីលេខៈ ៨១៣
ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១
សាលក្រមលេខៈ ០១៩..(ជ)
ចុះថ្ងៃទី២៧ខែមេសា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការនៃសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ។

-កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ។

-កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង១០ និង ០០ នាទី ព្រឹក ។

**ចៅក្រម** ៖ លោក [redacted]
**ក្រឡាបញ្ជី** ៖ លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងរដ្ឋប្បវេណីលេខៈ ៨១៣ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមាន៖

-ភាគីដើមចោទឈ្មោះ [redacted] សុង ភេទ ប្រុស អាយុ ៦៦ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅ [redacted] ។

ដោយមានមេធាវី [redacted] អត្តលេខ ១៧៦១ និង មេធាវី ឈ្មោះ [redacted] អត្តលេខ ១៩៧១ ជាអ្នកតំណាងដោយអាណត្តិ ។

-ភាគីចុងចម្លើយឈ្មោះ [redacted] ហ៊ួរ ភេទ ប្រុស អាយុ ៦០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅ [redacted] ។

ដោយមានមេធាវី [redacted] អត្តលេខ ២០៦០T ជាអ្នកតំណាងដោយអាណត្តិ ។

## អង្គហេតុនិងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលភាគីដើមចោទបានទាមទារមាន៖

១.១.ទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ២១០/២០១០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០១០ ជាលិខិតខុសច្បាប់។

១.២.បង្គាប់ឱ្យចុងចម្លើយប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខក.ណ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ មកឲ្យ [redacted] សុង ឬក៏ឱ្យចុងចម្លើយចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឡប់

ពីឈ្មោះ [redacted] ហ្សូរ មកឈ្មោះ [redacted] សុង វិញ ដោយដូរនឹងការទូទាត់ប្រាក់ដើម និងការប្រាក់ចំនួន ៤០,០០០$ (បួនម៉ឺន) ដុល្លារអាមេរិក ។

១.៣.ក្នុងករណីចុងចម្លើយមិនព្រមប្រគល់ប័ណ្ណទេ សុំមោឃភាពប័ណ្ណ សុំឱ្យតុលាការបង្គាប់ទៅមន្ត្រីសុរិយោដី ធ្វើការចុះបញ្ជីកម្មសិទ្ធិដោយដាក់ឈ្មោះ [redacted] សុង ជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុទំហំ ៦៤,៥០០ម៉ែត្រក្រឡា ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ហ្សូរ ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ។

១.៤.ចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**២.ខ្លឹមសារនៃសាលក្រមដែលភាគីដើមចោទនៃបណ្តឹងតបបានទាមទារមាន៖**

២.១.ច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ ធ្វើឡើងដោយដើមចោទឈ្មោះ [redacted] សុង លើចំណុចទាមទារទាំងមូល ។

២.២.បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សុង សងសំណងខូចខាត និងជម្ងឺចិត្តចំនួន ៥០,០០០$ (ប្រាំម៉ឺន) ដុល្លារសហរដ្ឋអាមេរិក ។

២.៣.បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សុង ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

## អង្គហេតុដែលជាមូលហេតុនៃការទាមទារ

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដើមចោទឈ្មោះ [redacted] សុង បានទៅខ្ចីប្រាក់ពីចុងចម្លើយឈ្មោះ [redacted] ហ្សូរ ចំនួន ៣០,០០០$ (បីម៉ឺន) ដុល្លារសហរដ្ឋអាមេរិក ហើយបានដាក់បញ្ចាំដី ដោយបានធ្វើការផ្ទេរសិទ្ធិកាន់កាប់ដីដែលជាកម្មសិទ្ធិរបស់ខ្លួននូវដីទំហំ ៦៤.៥០០ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងប្រជាជន ខាងកើតទល់នឹង [redacted] ហ្សូរ មានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ដើម្បីជានាសំណងដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ (មានការប្រាក់) ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ។

បន្ទាប់ពីដើមចោទឈ្មោះ [redacted] សុងបានខ្ចីមក ដើមចោទឈ្មោះ [redacted] សុងបានបង់ការប្រាក់មួយចំនួន ហើយក្រោយមកទៀតមិនមានលទ្ធភាពបង់ការប្រាក់ និងសងប្រាក់ដើម ទៅចុងចម្លើយ [redacted] ហ្សូរ ឡើយ ឡើយ ដោយយល់ឃើញថា នៅក្នុងកិច្ចសន្យាបានសរសេរថា នៅពេលដែលដើមចោទឈ្មោះ [redacted] សុងមានប្រាក់សងទៅគាត់ (ចុងចម្លើយ [redacted] ហ្សូរ) គ្រប់ចំនួននោះ ដើមចោទឈ្មោះ [redacted] សុងនឹងទទួលបានដីដែលដើមចោទឈ្មោះ [redacted] សុងបានដាក់បញ្ចាំមកវិញ។ ក្រោយមកដើមចោទឈ្មោះ [redacted] សុង បានយកប្រាក់ទៅសងគាត់ ក៏ប៉ុន្តែ ចុងចម្លើយលោក [redacted] ហ្សូរ មិនព្រមទទួលយកឡើយ គាត់ចង់បានដីរបស់ដើមចោទឈ្មោះ [redacted] សុង ដោយគាត់បានចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឈ្មោះគាត់ដូចមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៨១៣០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ដោយអត្តនោម័តខ្លួនគាត់មិនមានការយល់ព្រមពីដើមចោទឈ្មោះ [redacted] សុង [redacted] សុង ជាម្ចាស់កម្មសិទ្ធិឡើយ។ ការណ៍ដែលគាត់ធ្វើនេះបានធ្វើឱ្យដើមចោទឈ្មោះ សុងបាត់បង់ទ្រព្យសម្បត្តិខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ពីព្រោះដើមចោទឈ្មោះ [redacted] សុងធ្វើ



Scanned with CamScanner

លិខិតផ្ទេរកម្មសិទ្ធិកាន់កាប់ដីឱ្យគាត់ ពីព្រោះគាត់បានអះអាងថា មិនចង់បានដីដើមចោទឈ្មោះ [redacted] សុងទេ គ្រាន់តែធ្វើឱ្យមានភាពទុកចិត្តគ្នាតែប៉ុណ្ណោះ ប៉ុន្តែគាត់បែរជាធ្វើផ្ទុយពីការអះអាងរបស់គាត់។ ដូច្នេះទើបដើមចោទឈ្មោះ [redacted] សុង សម្រេចចិត្តដាក់ពាក្យបណ្តឹងដើម្បីសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចមានក្នុងកម្មវត្ថុនៃបណ្តឹងខាងលើ ។

## អង្គហេតុដែលជាមូលហេតុនៃការទាមទារនៃបណ្តឹងតប

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ កូនបំណុលឈ្មោះ [redacted] សុង បានខ្ចីប្រាក់ចំនួន USD ៣០.០០០ (បីម៉ឺនដុល្លាសហរដ្ឋអាមេរិក) ដោយមានការប្រាក់ពីម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ ហើយកូនបំណុលបានយល់ព្រមដាក់បញ្ចាំដីដែលមានទំហំ ៦៤.៥០០ម៉ែ ($ម^2$) (ហុកសិបបួនពាន់ប្រាំរយម៉ែត្រការ៉េ) ស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ឲ្យម្ចាស់បំណុល ដើម្បីធ្វើជាការធានាសំណង។

ក្រោយពីទទួលបានប្រាក់កម្ចីរួចហើយ កូនបំណុលឈ្មោះ [redacted] សុង ពុំបានគោរពកាតព្វកិច្ចបង់ការប្រាក់ប្រចាំខែឲ្យមកម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ ឡើយ។ កូនបំណុលឈ្មោះ [redacted] សុង បានស្នើសុំពន្យាពេលម្តងហើយម្តងទៀត ក្នុងការទូទាត់បំណុលមកឲ្យម្ចាស់បំណុល តែកូនបំណុលមិនបានគោរពតាមការស្នើសុំរបស់ខ្លួនឡើយ។ ដើម្បីឲ្យម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ មានការជឿជាក់ក្នុងសំណើរសុំពន្យាពេលជាថ្មីក្នុងការទូទាត់បំណុល កូនបំណុលឈ្មោះ [redacted] សុង បានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរដោយកំណត់ពេលជាក់លាក់ ដើម្បីធ្វើការដោះស្រាយសំណង។ ជាក់ស្តែង ក្នុងកិច្ចសន្យា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ (*ឯកសារ២*) កូនបំណុលឈ្មោះ [redacted] សុង បានសន្យាថានឹងដោះស្រាយនូវសំណងទាំងអស់ដែលបានខ្ចីពីម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ ឲ្យអស់មុនថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១។ ក៏ប៉ុន្តែកូនបំណុលឈ្មោះ [redacted] សុង នៅតែមិនគោរពកិច្ចសន្យានេះ។ តាមការស្នើសុំរបស់កូនបំណុលឈ្មោះ [redacted] សុង ម្ចាស់បំណុលក៏សុខចិត្តយល់ព្រមពន្យាពេលទូរទាត់សំណងជាថ្មីម្តងទៀត ហើយកូនបំណុលឈ្មោះ [redacted] សុង ក៏បានធ្វើកិច្ចសន្យាមួយទៀតចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១ (*ឯកសារ៣*) ដោយសន្យាថានឹងដោះស្រាយនូវសំណងទាំងអស់ដែលបានខ្ចីពីម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ ឲ្យអស់ត្រឹមថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១។ ក៏ប៉ុន្តែកូនបំណុលឈ្មោះ [redacted] សុង នៅតែមិនអាចរកប្រាក់មកទូទាត់បំណុលរបស់ខ្លួនបានតាមកាលបរិច្ឆេទកំណត់។

ដោយហេតុថា កូនបំណុលឈ្មោះ [redacted] សុង មិនមានលទ្ធភាពក្នុងការសងបំណុលរបស់ខ្លួន កូនបំណុលក៏បានស្នើសុំចរចារឲ្យធ្វើការដោះដូរបំណុលជាមួយដីបញ្ចាំ ពីព្រោះដីបញ្ចាំនៅពេលនោះមានតម្លៃប្រហាក់ប្រហែលនឹងបំណុលរបស់កូនបំណុល។ ក្រោយពីមានការស្នើសុំសម្របសម្រួលពីកូនបំណុល ទើបម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ សុខចិត្តយល់ព្រមតាមសំណូមពររបស់កូនបំណុលក្នុងការដោះដូរបំណុលជាមួយដីបញ្ចាំ ដើម្បីកាត់បន្ថយការលំបាករបស់កូនបំណុល។

ក្រោយពីទទួលបានការយល់ព្រមស្ម័គ្រចិត្តពីកូនបំណុលហើយ ម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ ក៏ធ្វើការរៀបចំដាក់ពាក្យស្នើសុំចុះបញ្ជីដី នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ទៅប្រធានការិយាល័យ

រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុកពញាឮ ដើម្បីស្នើសុំធ្វើកម្មសិទ្ធិ និងចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។ សូមបញ្ជាក់ថា ក្នុងនីតិវិធីស្នើសុំប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ អាជ្ញាធរមានសមត្ថកិច្ចបានធ្វើសេចក្តីជូនដំណឹង និង ផ្សព្វផ្សាយជាសាធារណៈស្របតាមនីតិវិធីនៃការចុះបញ្ជីដីធ្លីជាធរមាន។ ដោយហេតុថា កូនបំណុលឈ្មោះ [redacted] **សុង** បានស្នើសុំម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួរ ឲ្យដោះដូរបំណុលជាមួយដីបញ្ចាំ ទើបកូនបំណុលឈ្មោះ [redacted] **សុង** ពុំបានធ្វើការតវ៉ាទាមទារណាមួយឡើយ ទាំងអំឡុងពេលនីតិវិធីនៃការចុះបញ្ជីដីធ្លី និង ក្រោយពេលដែលមន្ត្រីសុរិយោដីបានចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។ ដូចនេះ គិតមកដល់ពេលបច្ចុប្បន្ន មានរយៈពេលប្រហែល០៨(ប្រាំបី)ឆ្នាំហើយ។

ដោយឃើញថា ដីក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ បានកើនតម្លៃក្នុងពេលបច្ចុប្បន្ន ដើមចោទឈ្មោះ [redacted] សុង មានចេតនាមិនស្មោះត្រង់ ក្នុងការទាមទារយកដីនេះមកវិញ ហើយបានធ្វើពាក្យបណ្តឹងដោយប្រើសិទ្ធិដោយបំពាន ដើម្បីបង្កភាពស្មុគស្មាញដល់ឈ្មោះ [redacted] ហ៊ួរ ដែលជាកម្មសិទ្ធិករស្របច្បាប់លើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។

**សេចក្តីថ្លែងការណ៍របស់ភាគី**

-មេធាវីតំណាងដោយអាណត្តិរបស់ដើមបណ្តឹងឈ្មោះ [redacted] សុង បានធ្វើសេចក្តីថ្លែងការថាខ្លួនស្នើសុំតុលាការៈ

១.ទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ២១០/២០១០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ ជាលិខិតខុសច្បាប់។

ដោយហេតុថា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ កូនក្តីខ្លួន បានទៅខ្ចីប្រាក់ពីលោក [redacted] ហ៊ួរ ចំនួន ៣០,០០០$ ដោយដាក់បញ្ចាំដី ដោយធ្វើការផ្ទេរសិទ្ធិកាន់កាប់ដី ដែលជាកម្មសិទ្ធិរបស់ខ្លួន នូវដីទំហំ ៦៤,៥០០ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ហ៊ួរ ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ដើម្បីធានាសំណង ពីព្រោះវាជាលក្ខខណ្ឌដែលលោក [redacted] ហ៊ួរ ដាក់ឱ្យប្រសិនបើ មិនផ្ទេរសិទ្ធិកាន់កាប់ដូច្នេះទេ គឺលោក [redacted] ហ៊ួរ គាត់មិនព្រមប្រគល់លុយឱ្យទេ ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ មានការប្រាក់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ។

២.បង្គាប់ឱ្យចុងចម្លើយប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ មកឲ្យ [redacted] សុង ឬក៏ឱ្យចុងចម្លើយចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឡប់ពីឈ្មោះ [redacted] ហ៊ួរ មកឈ្មោះ [redacted] សុង វិញ ដោយដូរនឹងការទូទាត់ប្រាក់ដើម និងការប្រាក់ចំនួន ៤០,០០០$ (បួនម៉ឺន) ដុល្លារអាមេរិក ។

ដោយហេតុថា នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ មានការប្រាក់ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ប្រការ៥ បានចែងថា ក្នុងករណីពេលណា ភាគីខ (លោក [redacted] សុង ) មានប្រាក់គ្រប់ចំនួន ដើម្បីសងទៅឱ្យភាគី ក (លោក [redacted] ហ៊ួរ) វិញនោះ ភាគី ក ត្រូវធ្វើការកាត់ ផ្ទេរសិទ្ធិ កាន់កាប់ដី ចែងក្នុងប្រការ



Scanned with CamScanner

២ ទៅឱ្យភាគី ខ វិញភ្លាម ហើយបញ្ចប់ការខ្ចី ចាប់ពីពេលនោះតទៅ ។ ពេលនេះ កូនក្តីខ្លួន សូមប្រគល់ទឹកប្រាក់ចំនួន ៤០,០០០$ ទាំងដើម ទាំងការ ទៅឱ្យលោក [redacted] ហ៊ួរ វិញ ហើយលោក [redacted] ហ៊ួរ ត្រូវប្រគល់ ឬចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឡប់មកអោយឈ្មោះ [redacted] សុង វិញ ។

៣.ក្នុងករណីចុងចម្លើយមិនព្រមប្រគល់ប័ណ្ណទេ សុំមោឃភាពប័ណ្ណ សុំឱ្យតុលាការបង្គាប់ទៅមន្ត្រីសុរិយោដី ធ្វើការចុះបញ្ជីកម្មសិទ្ធិដោយដាក់ឈ្មោះ [redacted] សុង ជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុទំហំ ៦៤,៥០០ម៉ែត្រក្រឡា ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ហ៊ួរ ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ។

ដោយមូលហេតុថា កាលដែលដើមចោទ [redacted] សុង បានព្រមព្រៀងផ្ទេរសិទ្ធិកាន់កាប់ លើដីដែលជាកម្មសិទ្ធិរបស់ខ្លួន មកឱ្យលោក [redacted] ហ៊ួរ ដើម្បីជាការធានាសំណង (ដាក់បញ្ចាផ្តាច់) ជាការខុសច្បាប់ ពីព្រោះច្បាប់បានហាមកិច្ចសន្យាបញ្ចាំផ្តាច់ នៅក្នុងមាត្រា ២១០ នៃច្បាប់ភូមិបាលចែងថា ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យជាប់កិច្ចសន្យាបញ្ចាំបានឡើយ ។ ខ ណាដែលផ្ទុយនឹងបញ្ញត្តិនេះ ត្រូវទុកជាមោឃៈ ។

៤.ចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

-មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយឈ្មោះ [redacted] ហ៊ួរ បានធ្វើសេចក្តីថ្លែងការតបថាៈ

ចំពោះករណីទី១ "ដែលដើមចោទស្នើសុំទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ២១០/២០១០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ ជាលិខិតខុសច្បាប់សូមបដិសេធការទាមទាររបស់ ដើមចោទ"។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ លោក [redacted] ហ៊ួរ ពិតជាបានឱ្យលុយលោក [redacted] សុង ខ្ចីចំនួន ៣០,០០០$ ដោយលោក [redacted] សុង បានដាក់ដីបញ្ចាំទំហំ ៦៤,៥០០ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ហ៊ួរ ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល។ ប៉ុន្តែកាលដែលលោក [redacted] សុង បានផ្ទេរសិទ្ធិកាន់កាប់ដីនេះ មកឱ្យលោក [redacted] ហួរ គឺជាការព្រមព្រៀងរវាងគូរភាគីដូចបានបញ្ជាក់នៅក្នុងកិច្ចសន្យា ខ្ចីប្រាក់មានការប្រាក់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ។

ចំពោះករណីទី២ "ដែលដើមចោទស្នើសុំបង្គាប់ឱ្យចុងចម្លើយប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ០១៨១ ៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ឬក៏ឱ្យចុងចម្លើយចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឡប់ពីឈ្មោះ [redacted] ហួរ មកឈ្មោះ [redacted] សុង វិញ ដោយដូរនឹងការទូទាត់ប្រាក់ដើម និងការប្រាក់ចំនួន ៤០,០០០$ (បួនម៉ឺន) ដុល្លារអាមេរិក" ។ ខ្លួនសូមបដិសេធការទាមទាររបស់ភាគីខាងដើមចោទ ពីព្រោះកន្លងទៅ ក្រោយពីចុះកិច្ចសន្យាខ្ចីប្រាក់ មានការប្រាក់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ភាគីខាងដើមចោទ ដែលជាកូនបំណុល ពុំបានគោរពកាតព្វកិច្ចរបស់ខ្លួន ហើយបានស្នើសុំចុងចម្លើយដែលជាម្ចាស់បំណុល ម្តងហើយម្តងទៀត ក្នុងការពន្យាពេល អនុវត្តកាតព្វកិច្ចរបស់កូនបំណុល តែកូនបំណុលនៅតែមិនគោរពតាមកិច្ចសន្យារបស់ខ្លួន ដើម្បីឱ្យម្ចាស់បំណុល ជឿទុកចិត្តសារជាថ្មី កូនបំណុល បានធ្វើកិច្ចសន្យា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ដោយសន្យាថា នឹងដោះស្រាយសំណងទាំងអស់ឱ្យបានមុនថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ ជាកំណត់ តែដល់ថ្ងៃកំណត់ កូន.

បំណុល នៅតែមិនគោរពកិច្ចសន្យានោះទៀត កូនបំណុលក៏ធ្វើកិច្ចសន្យាមួយទៀត ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១ ដោយសន្យាថា នឹងដោះស្រាយសំណងទាំងអស់មកឱ្យម្ចាស់បំណុល ត្រឹមថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ ជាកំណត់ ក៏ប៉ុន្តែដល់ថ្ងៃកំណត់ កូនបំណុលនៅតែមិនមានលទ្ធភាពដោះស្រាយបំណុលរបស់ខ្លួន។កូនបំណុលក៏បានស្នើសុំឱ្យម្ចាស់បំណុលធ្វើការដោះដូរដីដាក់បញ្ចាំជាមួយបំណុលរបស់ខ្លួន។ ដោយមានការស្នើសុំពីខាងកូនបំណុល ហើយដើម្បី ដោះទុកលំបាករបស់កូនបំណុល ម្ចាស់បំណុលក៏បានយល់ព្រមតាមសំណើរនេះ ម្ចាស់បំណុលក៏បានធ្វើពាក្យស្នើសុំ ប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់អចលនវត្ថុលើដីនេះ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ហើយទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លើអចលនវត្ថុនេះ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ។ ដោយមានការស្នើសុំ និងយល់ព្រមពីកូនបំណុល ដូចបានរៀបរាប់ខាងលើហើយ ទើបកូនបំណុល មិនដែលធ្វើបណ្តឹងជំទាស់ណាមួយ ទាក់ទងទៅនឹងការស្នើសុំពាក្យធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ពីម្ចាស់បំណុល រហូតមកដល់ពេលបច្ចុប្បន្ននេះ ដែលមានរយៈពេលជាង ៨ឆ្នាំមកហើយ ។

ចំពោះចំណុចទី៣ ដែលដើមចោទស្នើសុំក្នុងករណីចុងចម្លើយមិនព្រមប្រគល់ប័ណ្ណ ទេ សុំមោឃភាពប័ណ្ណ សុំឱ្យតុលាការបង្គាប់ទៅមន្ត្រីសុរិយោដី ធ្វើការចុះបញ្ជីកម្មសិទ្ធិដោយដាក់ឈ្មោះ [redacted] សុង ជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុទំហំ ៦៤,៥០០ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ហ៊ួរ ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ។ខ្លួនសូមបដិសេធការទាមទារនេះ ដោយហេតុថា ការធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ពុំមែនជារឿងខុសច្បាប់ ពីព្រោះវាកើតឡើង ដោយការព្រមព្រៀងរវាងគូភាគី វាពុំមានហេតុផលណាមួយ ក្នុងការធ្វើមោឃភាពទៅលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះឡើយ ។

ចំពោះចំណុចទី៤ គឺស្នើសុំឱ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

-សេចក្តីថ្លែងការណ៍ នៃបណ្តឹងតបរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ នៃបណ្តឹងតបឈ្មោះ ង៉ោ ហ៊ួរ បានធ្វើសេចក្តីថ្លែងការណ៍ថា នៅក្នុងករណីនេះ កូនក្តីខ្លួន ក៏បានធ្វើបណ្តឹងតបផងដែរ ដោយស្នើសុំ៖

១.ច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ ធ្វើឡើងដោយដើមចោទឈ្មោះ [redacted] សុង លើចំណុចទាមទារទាំងមូល។ មូលហេតុនៃការទាមទារនេះ ខ្លួនបានធ្វើសេចក្តីថ្លែងការណ៍តប នៅចំណុចខាងលើស្រាប់ ។ ខ្លួនសូមបញ្ជាក់បន្ថែមថា ភាគីដើមចោទឈ្មោះ [redacted] សុង បានដាក់ពាក្យបណ្តឹងចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ នេះ គឺជាការឆ្លៀតឱកាស ដើម្បីយកដីមកវិញ ពីព្រោះតែដីបានកើនតម្លៃ ។ ដូចនេះ ពាក្យបណ្តឹងរបស់ដើមចោទ គឺជាបណ្តឹងខុសច្បាប់ ពីព្រោះដើមចោទ ពុំមានសិទ្ធិ ស្របច្បាប់ណាមួយក្នុងការធ្វើពាក្យបណ្តឹងនេះឡើយ ។

២.បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សុង សងសំណងខូចខាត និងជំងឺចិត្តចំនួន USD ៥០,០០០$ (ប្រាំម៉ឺន) ដុល្លារអាមេរិក ។ ដោយហេតុថា ពាក្យបណ្តឹងរបស់ដើមចោទ បានធ្វើឱ្យខូចខាតជាច្រើនដល់កូនក្តីខ្លួន ទាំងពេលវេលា ទាំងប្រាក់កាស ទាំងចំណាយលើសេវាផ្លូវច្បាប់ និង



Scanned with CamScanner

សោហ៊ុយធ្វើដំណើរ ចំណាយផ្សេងទៀត ដូចនេះ សាលាដំបូងខេត្តកណ្តាល គប្បីពិចារណាលើការទាមទារនេះ។

៣.បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សុង ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

-សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] សុង នៃបណ្តឹងតប បានធ្វើសេចក្តីថ្លែងការតប ថា៖

ចំពោះចំណុចទី២ គឺកិច្ចសន្យាដែលធ្វើឡើងដោយកូនក្តីរបស់ខ្លួនឈ្មោះ [redacted] សុង ជាមួយនឹងឈ្មោះ [redacted] ហ៊ួរ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១ ជាកិច្ចសន្យាខុសច្បាប់ ពីព្រោះកិច្ចសន្យានេះមានលក្ខណៈផ្ទុយគតិច្បាប់ ដែលច្បាប់ហាម មិនឱ្យមានកិច្ចសន្យាបញ្ចាំផ្តាច់ទេ ទោះបីមានការយល់ព្រមពីកូនបំណុលនៅក្នុងកិច្ចសន្យាក៏ដោយ។ រីឯទ្រព្យដែលដាក់ធានាលើបំណុលនោះ គ្រាន់តែជាមធ្យោបាយ ដើម្បីបញ្ជាក់អំពីសិទ្ធិដែលម្ចាស់សិទ្ធិលើការបញ្ចាំ និងទទួលបានសំណងវិញយ៉ាងពិតប្រាកដ ។ ដូច្នេះ ឈ្មោះ [redacted] ហ៊ួរ គ្មានសិទ្ធិយកលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ២១០/២០១០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ ដើម្បីជាកម្មវត្ថុនៃការចុះបញ្ជី ដើម្បីទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កណ ០១៨១៣០ ចុះថ្ងៃទី១៦ខែមករា ឆ្នាំ២០១២ នោះឡើយ ។ មូលហេតុ ដែលកូនក្តីរបស់ខ្លួន មិនបានធ្វើបណ្តឹងជំទាស់ ក្នុងការដាក់ពាក្យស្នើសុំ ដើម្បីទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កណ ០១៨១៣០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ដោយសារតែកូនក្តីរបស់ខ្លួន មិនបានដឹងឮ អំពីនីតិវិធីក្នុងការចុះបញ្ជីដីនេះទេ ហើយម្យ៉ាងទៀតសព្វថ្ងៃនេះ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សុង កំពុងកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើដីនោះរហូតមកដល់សព្វថ្ងៃនេះ ។

ចំពោះចំណុចទី៣ សូមបដិសេធន៍ចំពោះករណីដែលលើកឡើងថា មានការព្រមព្រៀងពីភាគីកូនក្តីខ្លួន ក្នុងការធ្វើប័ណ្ណ ពីព្រោះកូនក្តីខ្លួនមិនបានយល់ព្រម ឱ្យលោក [redacted] ហ៊ួរ យកលិខិតផ្ទេរសិទ្ធិកាន់កាប់នោះ ទៅចុះបញ្ជីដីដាក់ឈ្មោះ [redacted] ហ៊ួរ ជាម្ចាស់កម្មសិទ្ធិនោះឡើយ ។ កូនក្តីខ្លួនមិនបានបដិសេធន៍ ពីព្រោះតែគាត់មិនបានដឹង ហើយម្យ៉ាងដោយសារតែ ខ្លួនជាអ្នកកាន់កាប់ និងអាស្រ័យផលលើដីនោះ ។

ចំពោះបណ្តឹងតបវិញ ទាក់ទងនឹង៖

ចំណុចទី១ ខ្លួនសូមរក្សាពាក្យបណ្តឹងរបស់កូនក្តីខ្លួនដដែល ។ ដោយហេតុថា កូនក្តីខ្លួននៅតែជាកម្មសិទ្ធិករនៃអចលនទ្រព្យដីទំ ៦៤,៥០០ម៉ែត្រការ៉េ ដដែល ស្របទៅតាមច្បាប់ ពុំមានលក្ខខណ្ឌណាមួយដែលនាំឱ្យមានការថ្លោះសិទ្ធិនោះទេ ទោះបីជាមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីក៏ដោយ ពីព្រោះតែលិខិតផ្ទេរសិទ្ធិនេះ កូនក្តីខ្លួនយល់ព្រមផ្តិតមេដៃ ដើម្បីជាការធានាសំណងតែប៉ុណ្ណោះ ដូចនៅក្នុងកិច្ចសន្យា ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ហើយកូនក្តីខ្លួនក៏មិនបានយល់ព្រមឬក៏អនុញ្ញាតឱ្យលោក [redacted] ហ៊ួរ យកទៅចុះបញ្ជីដាក់ឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះទេ ។

ចំណុចទី២ សូមបដិសេធន៍ការទាមទារសំណងជំងឺចិត្តចំនួន ៥០,០០០$ ។ ការដែលលោក [redacted] ហ៊ួរ យកលិខិតផ្ទេរសិទ្ធិទៅចុះបញ្ជីផ្ទេរកម្មសិទ្ធិ គឺពុំមានការអនុញ្ញាតពីកូនក្តីរបស់ខ្លួនឡើយ ហើយកូនក្តីខ្លួនក៏ធ្លាប់យកប្រាក់ទៅសងគាត់វិញដែរ តែគាត់មិនព្រមទទួលយក បែរជាយកលិខិតផ្ទេរសិទ្ធិនោះ ទៅផ្ទេរដាក់ឈ្មោះខ្លួនឯង [redacted] ហ៊ួរ ជាម្ចាស់កម្មសិទ្ធិករទៅវិញ ។



Scanned with CamScanner

## ចំណុចវិវាទ

តើលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ២១០/២០១០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ ជាលិខិតខុសច្បាប់ ឬក៏ជាលិខិតត្រឹមត្រូវតាមច្បាប់?

## សំអាងហេតុ

ឆ្លងកាត់តាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងក្រោយពីបានពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់រួចហើយ តុលាការយល់ឃើញថា៖

១.ចំពោះបណ្តឹងទាមទាររបស់ដើមចោទឈ្មោះ [redacted] សុង និងចម្លើយឈ្មោះ [redacted] ហ៊ួរ ៖

១.១.តាមសេចក្តីថ្លែងការណ៍របស់ភាគីអ្នកតំណាងដោយអាណត្តិខាងដើមចោទ បានលើកឡើងថា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ កូនក្តីខ្លួនបានទៅខ្ចីប្រាក់ពីលោក [redacted] ហ៊ួរ ចំនួន ៣០,០០០$(បីម៉ឺន) ដុល្លារសហរដ្ឋអាមេរិក ដោយដាក់បញ្ចាំដី ហើយធ្វើការផ្ទេរសិទ្ធិកាន់កាប់ដីដែលជាកម្មសិទ្ធិរបស់ខ្លួននូវដីទំហំ ៦៤,៥០០ម៉ែត្រការ៉េ ដើម្បីធានាសំណង ពីព្រោះវាជាលក្ខខណ្ឌដែលលោក [redacted] ហ៊ួរ ដាក់ឱ្យ ប្រសិនបើមិនផ្ទេរសិទ្ធិកាន់កាប់ដូច្នេះទេ គឺលោក [redacted] ហ៊ួរ គាត់មិនព្រមប្រគល់លុយឱ្យឡើយ ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ មានការប្រាក់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១០ ។

១.២.តាមភាគីអ្នកតំណាងដោយអាណត្តិខាងចុងចម្លើយឈ្មោះ [redacted] ហ៊ួរ បានធ្វើសេចក្តីថ្លែងការណ៍តបថា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ លោក [redacted] ហ៊ួរ ពិតជាបានឱ្យលុយលោក [redacted] សុង ខ្ចីចំនួន ៣០,០០០$ មែន ដោយលោក [redacted] សុង បានដាក់ដីបញ្ចាំទំហំ ៦៤,៥០០ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ហ៊ួរ ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល។ ប៉ុន្តែកាលដែលលោក [redacted] សុង បានផ្ទេរសិទ្ធិកាន់កាប់ដីនេះ មកឱ្យលោក [redacted] ហ៊ួរ គឺជាការព្រមព្រៀងរវាងគូភាគីដូចបានបញ្ជាក់នៅក្នុងកិច្ចសន្យា ខ្ចីប្រាក់មានការប្រាក់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១០ ។

*ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ដោយមានការប្រាក់ ចំនួន ៣០,០០០$(បីម៉ឺន) ដុល្លារសហរដ្ឋអាមេរិក និងដាក់បញ្ចាំដីទំហំ ៦៤,៥០០(ប្រាំមួយម៉ឺន បួនពាន់ ប្រាំរយ) ម៉ែត្រការ៉េ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ តុលាការយល់ឃើញថា នៅក្នុងករណីនេះ ភាគីខាងដើមចោទ គឺបានបង្ហាញឆន្ទៈក្នុងការផ្ទេរសិទ្ធិកាន់កាប់ទៅឱ្យភាគីខាងចុងចម្លើយប្រាកដមែន ពីព្រោះយោងតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ បានបង្ហាញឱ្យឃើញថា ការផ្ទេរសិទ្ធិកាន់កាប់នេះ បានធ្វើឡើងដោយមានការព្រមព្រៀង និងស្ម័គ្រចិត្តដោយគ្មានការបង្ខិតបង្ខំ រវាងគូភាគីដើមចោទ ដែលជាកូនបំណុលឈ្មោះ [redacted] សុង និងភាគីចុងចម្លើយដែលជាម្ចាស់បំណុលឈ្មោះ [redacted] ហ៊ួ ហើយក៏មានការបញ្ជាក់ទទួលស្គាល់លើលិខិតដោយអាជ្ញាឃុំថែមទៀតផង។ ជាងនេះទៅទៀត នៅក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ នោះ គឺមិនមានការបង្ហាញឆន្ទៈដោយមានវិការៈ ដែលនាំឱ្យមានការលុបចោលកិច្ចសន្យានោះឡើយ ពីព្រោះដោយហេតុថា ការបង្ហាញ…*

*ឆន្ទៈខាងលើ មិនបានធ្វើឡើងក្រោមទម្រង់នៃការភាន់ច្រលំ ការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញឆន្ទៈមិនពិត និងការឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុនោះទេ ដូច្នេះភាគីខាងដើមចោទមិនអាចស្នើសុំឱ្យតុលាការធ្វើការលុបចោលកិច្ចសន្យានោះបានទេ ។*

២.ចំណែកការទាមទារនៃបណ្ដឹងតបវាំងដើមចោទនៃបណ្ដឹងតបឈ្មោះ [redacted] ហ៊ួ និងចុងចម្លើយនៃបណ្ដឹងតបឈ្មោះ [redacted] សុង វិញ តុលាការយល់ឃើញថា ៖

២.១.តាមសេចក្ដីថ្លែងការណ៍នៃបណ្ដឹងតប របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទនៃ បណ្ដឹងតបឈ្មោះ [redacted] ហ៊ួរ បានធ្វើសេចក្ដីថ្លែងការណ៍ថា នៅក្នុងករណីនេះ កូនក្ដីខ្លួន ក៏បានធ្វើបណ្ដឹងតបផងដែរ ដោយស្នើសុំដូចតទៅ។ ទី១ ច្រានចោលពាក្យបណ្ដឹង ចុះថ្ងៃទី១៣ ខែវិច្ឆិការ ឆ្នាំ២០២០ ធ្វើឡើងដោយដើមចោទឈ្មោះ [redacted] សុង លើចំណុចទាមទារទាំងមូល។ មូលហេតុនៃការទាមទារនេះ ខ្លួនបានធ្វើសេចក្ដីថ្លែងការណ៍តប នៅចំណុចខាងលើស្រាប់ ។ ខ្លួនសូមបញ្ជាក់បន្ថែមថា ភាគីដើមចោទឈ្មោះ [redacted] សុង បានដាក់ពាក្យបណ្ដឹងចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ នេះ គឺជាការឆ្លៀតឱកាស ដើម្បីយកដីមកវិញ ពីព្រោះតែដីបានកើនតម្លៃ ។ ដូចនេះ ពាក្យបណ្ដឹងរបស់ដើមចោទ គឺជាបណ្ដឹងខុសច្បាប់ ពីព្រោះដើមចោទ ពុំមានសិទ្ធិ ស្របច្បាប់ណាមួយក្នុងការធ្វើពាក្យបណ្ដឹងនេះឡើយ។ ទី២ បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សុង សងសំណងខូចខាត និងជំងឺចិត្តចំនួន USD ៥០,០០០$ (ប្រាំម៉ឺន) ដុល្លារអាមេរិក ។ ដោយហេតុថា ពាក្យបណ្ដឹងរបស់ដើមចោទ បានធ្វើឱ្យខូចខាតជាច្រើនដល់កូនក្ដីខ្លួន ទាំងពេលវេលា ទាំងប្រាក់កាស ទាំងចំណាយលើសេវាផ្លូវច្បាប់ និងសោហ៊ុយធ្វើដំណើរ ចំណាយផ្សេងទៀត ដូចនេះ សាលាដំបូងខេត្តកណ្ដាល គប្បីពិចារណាលើការទាមទារនេះ។ និងទី៣ បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សុង ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

២.២.តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយនៃបណ្ដឹងតបឈ្មោះ ផេង សុង បានធ្វើសេចក្ដីថ្លែងការណ៍តបវិញថា ចំណុចទី១ ខ្លួនសូមរក្សាពាក្យបណ្ដឹងរបស់កូនក្ដីខ្លួនដដែល ។ ដោយហេតុថា កូនក្ដីខ្លួន នៅតែជាកម្មសិទ្ធិករនៃអចលនទ្រព្យដីទំ ៦៤,៥០០ ម៉ែត្រការ៉េ ដដែល ស្របទៅតាមច្បាប់ ពុំមានលក្ខខណ្ឌណាមួយដែលនាំឱ្យមានការផ្លោះសិទ្ធិនោះទេ ទោះបីជាមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីក៏ដោយ ពីព្រោះតែលិខិតផ្ទេរសិទ្ធិនេះ កូនក្ដីខ្លួនយល់ព្រមផ្ដិតមេដៃ ដើម្បីជាការធានាសំណងតែប៉ុណ្ណោះ ដូចនៅក្នុងកិច្ចសន្យា ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ហើយកូនក្ដីខ្លួនក៏មិនបានយល់ព្រម ឬក៏អនុញ្ញាតឱ្យលោក [redacted] ហ៊ួរ យកទៅចុះបញ្ជីដាក់ឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះទេ។ ចំណុចទី២ សូមបដិសេធន៍ការទាមទារសំណងជំងឺចិត្តចំនួន ៥០,០០០$ ។ ការដែលលោក [redacted] ហ៊ួរ យកលិខិតផ្ទេរសិទ្ធិទៅចុះបញ្ជីផ្ទេរកម្មសិទ្ធិ គឺពុំមានការអនុញ្ញាតពីកូនក្ដីរបស់ខ្លួនឡើយ ហើយកូនក្ដីខ្លួនក៏ធ្លាប់យកប្រាក់ទៅសងគាត់វិញដែរ តែគាត់មិនព្រមទទួលយក បែរជា យកលិខិតផ្ទេរសិទ្ធិនោះ ទៅផ្ទេរដាក់ឈ្មោះខ្លួនឯង [redacted] ហ៊ួរ ជាម្ចាស់កម្មសិទ្ធិករទៅវិញ ។

*ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ (មានការប្រាក់) ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០, លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចុះថ្ងៃទី*

*១៦ ខែមករា ឆ្នាំ២០១២ ធ្វើឱ្យតុលាការជឿជាក់ថា ក្រោយពីភាគីខាងដើមចោទឈ្មោះ [redacted] សុង បានធ្វើលិខិតផ្ទេរសិទ្ធិនោះហើយ អស់ រយៈពេល ៨ឆ្នាំ ៩ខែ ២៧ថ្ងៃ មក គឺពុំមានការជំទាស់ ឬប្តឹងតវ៉ាអ្វីឡើយ ដោយទើបតែថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក៏ភាគីខាងដើមចោទបានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តកណ្តាល ដោយអះអាងថា ខ្លួនមិនបានព្រមព្រៀងផ្ទេរសិទ្ធិលើដីដាក់បញ្ចាំឱ្យទៅភាគីចុងចម្លើយទៅវិញ ទោះបីជាភាគីខាងដើមឈ្មោះ [redacted] សុង បានទទួលដំណឹងអំពីការចុះបញ្ជីនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លើអចលនវត្ថុនោះរួចហើយក៏ដោយ ក៏ខ្លួនមិនមានការប្តឹងតវ៉ាអ្វីដែរ ដែលទង្វើរបស់ភាគីដើមចោទឈ្មោះ [redacted] សុង គឺបានបញ្ជាក់យ៉ាងច្បាស់អំពីចេតនាទុច្ចរិតរបស់ភាគីខាងដើមចោទ ចំពោះភាគីចុងចម្លើយនៅពេលដែលដី(អចលនវត្ថុនៃការបញ្ចាំ)ដែលបានផ្ទេរសិទ្ធិទៅឱ្យភាគីខាងចុងចម្លើយ បានកើនតម្លៃ ក៏មានគំនិតទុច្ចរិតចង់បានដីនោះមកវិញ ដែលអស់រយៈពេលជាង ៨ឆ្នាំមកហើយ បើភាគីខាងដើមចោទសុច្ចរិត និងស្មោះត្រង់មែន ពិតជាប្តឹងតវ៉ាតាំងតែពីកើតឡើងនូវបញ្ហានេះដំបូងមកម្លេះ ដោយមិនអូសបន្លាយរយៈទុកចោលអស់ជាង៨ឆ្នាំទើបប្តឹងនោះទេ ។ នៅក្នុងករណីនេះ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ(ដី) ដែលបានដាក់បញ្ចាំទៅឱ្យភាគីចុងចម្លើយឈ្មោះ [redacted] ហ៊ួ គឺធ្វើឡើងដោយការព្រមព្រៀង និងស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំលើភាគីដើមចោទឈ្មោះ [redacted] ហ៊ួ នោះទេ។*

៣.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ឡេន ជាមេឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល បានឆ្លើយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា មានសុរិយោដីស្រុកបង្ខំឱ្យខ្លួនចុះហត្ថលេខា បើខ្លួនមិនចុះហត្ថលេខាទេ គេថាខ្លួនខុស។ ការពិតគេពិតជាបង្ខំខ្លួនមែន គេនិយាយថាប្រយ័ត្នជាប់គុក ពីព្រោះឈ្មោះ [redacted] សុង ជំពាក់លុយគេ ។ ចំពោះលិខិតផ្ទេរសិទ្ធិ មិនបានធ្វើនៅចំពោះមុខខ្លួនទេ ហើយឈ្មោះ [redacted] ហ៊ួ មិនដែលទៅកាន់កាប់ដីនោះឡើយ គាត់មានតែប័ណ្ណទេ ។ ពេលខ្លួនចុះហត្ថលេខា គឺមានគេបង្ខំខ្លួន ដោយឈ្មោះ [redacted] ហោងធី មន្ត្រីសុរិយោដីស្រុកជាអ្នកយកលិខិតឱ្យខ្លួនចុះហត្ថលេខា ។

*តាមការអះអាងរបស់សាក្សីឈ្មោះ [redacted] ឡេន ដែលជាអាជ្ញាធរមានសមត្ថកិច្ច (មេឃុំទំនប់ធំ) ថា ខ្លួនចុះហត្ថលេខាលើលិខិតនោះ(លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០) គឺធ្វើឡើងដោយការបង្ខិតបង្ខំទៅវិញ ដែលនៅក្នុងករណីនេះ តុលាការជឿជាក់ថា ចម្លើយរបស់សាក្សី គឺធ្វើឡើងមិនពិតនោះទេ ពីព្រោះក្នុងនាមជាមេឃុំ ដែលជាអាជ្ញាធរមូលដ្ឋានថ្នាក់លើនៃឃុំមួយរូប បើចេះតែចុះហត្ថលេខា ហើយប្រកែកមិនទទួលខុសត្រូវលើហត្ថលេខារបស់ខ្លួនដែលបានធ្វើរួចហើយតើនឹងទៅជាយ៉ាងណាទៅវិញ? ក្នុងនាមជាមេឃុំ មិនអាចនិយាយប្រែប្រួលក្រឡាស់ តាមតែអំពើចិត្តនោះឡើយ ហើយអ្វីដែលសំខាន់ គឺសាក្សីបានចុះហត្ថលេខា និងបោះត្រាបញ្ជាក់យ៉ាងច្បាស់លាស់នៅលើខិតថែមទៀតផង ដែលនេះជាការទទួលខុសត្រូវលើទង្វើរបស់ខ្លួន ក្នុងនាមជាអាជ្ញាធរមានសមត្ថកិច្ច ហើយចំពោះការបំពេញភារកិច្ចរបស់អាជ្ញាធរឃុំ គឺគ្មានអ្នកណាម្នាក់ហ៊ានបំពានទៅលើភារកិច្ចរបស់រដ្ឋបាលឃុំ ដែលត្រូវធ្វើការងារបម្រើប្រជាពលរដ្ឋ ដោយគោរពតាមច្បាប់នោះដែរ។*

៤.អ្នកតំណាងដោយអាណត្តិរបស់ភាគីខាងដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] ហ៊ួរ បានដាក់ពាក្យប្តឹងទាមទារសងសំណងការខូចខាត និងជំងឺចិត្ត ចំនួន USD ៥០,០០០$ (ប្រាំម៉ឺន)

ដុល្លារអាមេរិក ដោយលើកហេតុផលថា ពាក្យបណ្តឹងរបស់ដើមចោទ បានធ្វើឱ្យខូចខាតជាច្រើនដល់កូនក្តីខ្លួន ទាំងពេលវេលា ទាំងប្រាក់កាស ទាំងចំណាយលើសេវាផ្លូវច្បាប់ និងសោហ៊ុយធ្វើដំណើរ ចំណាយផ្សេងទៀត ដែលនៅក្នុងករណីនេះ តុលាការយល់ឃើញថា ការទាមទារនេះ គឺមានចំនួនច្រើន គប្បីតុលាការធ្វើការសម្រេចប្រាក់សំណងជំងឺចិត្ត ត្រឹមចំនួន ៨,០០០,០០០៛ (ប្រាំបីលាន) រៀល។

៥.ភាគីខាងចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted] សុង ជាអ្នកទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីផ្អែកតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចែងថា ពន្ធជាបន្ទុករបស់អ្នកចាញ់ក្តី ដែលមានបង្កាន់ដៃបង់ប្រាក់ លេខ ២៦-១-០០៦២៤៧៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ គឺមានចំនួន ៧៩០,០០០៛ (ប្រាំពីរសែន ប្រាំបួនម៉ឺន) រៀល ។

## សេចក្តីសម្រេចបញ្ចប់

១.ច្រានចោលការទាមទាររបស់ដើមបណ្តឹងឈ្មោះ [redacted] សុង លើចំណុចនៃការទាមទារទាំងមូល ។

២.បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សុង សងប្រាក់ការខូចខាត ចំនួន ៨,០០០,០០០៛ (ប្រាំបីលាន) រៀល មកឱ្យចុងចម្លើយឈ្មោះ [redacted] ហ៊ួរ ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ ។

សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ចំពោះមុខគូភាគី ។

បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

កណ្តាល ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner